THE SCHOOL DISTRICT OF PHILADELPHIA

**ស្នងការដ្ឋាន**
440 North Broad Street
Philadelphia, PA 19130

**William R. Hite, Jr., Ed.D.**
ស្នងការ

5 កុម្ភៈ 2021

ជូនចំពោះក្រុមគ្រួសាររបស់មណ្ឌលសិក្សាធិការនៃក្រុង Philadelphia ជាទីរាប់អាន

នៅថ្ងៃចន្ទ យើងស្វាគមន៍គ្រូបង្រៀន PreK-2 និងបុគ្គលិកតាមសាលារៀនរបស់ពួកយើងឲ្យត្រឡប់ទៅសាលារៀនវិញ ដើម្បីឲ្យពួកគេអាចចូលរួមក្នុងការអភិវឌ្ឍវិជ្ជាជីវៈ ដើម្បីពង្រឹងបន្ថែមនូវជំនាញបង្រៀនរបស់ពួកគេ និងជួយរៀបចំថ្នាក់រៀនរបស់ពួកគេ ដើម្បីឲ្យយើងអាចចាប់ផ្តើមរៀបចំការសិក្សាបន្តិចម្តងៗ និងដោយប្រុងប្រយ័ត្នតាមដំណាក់កាល ដើម្បីបញ្ចូលសិស្សានុសិស្ស PreK-2 របស់យើងទៅក្នុងការសិក្សានៅសាលារៀនជាលើកដំបូងក្នុងអំឡុងពេលជិតមួយឆ្នាំមកនេះ។ បុគ្គលិកទាំងនេះកំពុងចូលរួមជាមួយនឹងនាយកសាលា វិស្វករអគារ និងមណ្ឌលនិងបុគ្គលិកថែទាំផ្សេងទៀត បុគ្គលិកនៃសេវាកម្មដឹកជញ្ជូននិងអាហាររាប់រយនាក់ ដែលបាននឹងកំពុងធ្វើការដោយសុវត្ថិភាពនៅក្នុងសាលារៀនតាំងពីរដូវផ្ការីកនៃឆ្នាំ 2020 មកម្ល៉េះ ដើម្បីដាក់ចេញនូវកម្រិតសុខភាពនិងសុវត្ថិភាពជាច្រើនដែលបានបង្ហាញពីការកាត់បន្ថយហានិភ័យនៃការចម្លងជំងឺ COVID-19 នៅពេលដែលបានអនុវត្ត -- ពីឧបករណ៍ការពារផ្ទាល់ខ្លួនសម្រាប់សិស្សានុសិស្សនិងបុគ្គលិកទាំងអស់ ការរៀបចំថ្នាក់រៀន និងបន្ទប់ទឹកជាថ្មីចំពោះការរក្សាគម្លាតសង្គម និងរបាំងប្លាស្ទិកក្រាស់ថ្លានៅក្នុងការិយាល័យ ទៅជាកន្លែងលាងសម្អាតដៃនិងកន្លែងផ្តល់ទឹកពិសាដែលមិនចាំបាច់ប៉ះផ្ទាល់ ផ្ទាំងណែនាំសុវត្ថិភាព ការធ្វើតេស្តប្រព័ន្ធបន្សុទ្ធខ្យល់នៅគ្រប់សាលារៀនទាំងអស់ និងការជួលជុល ការធ្វើឲ្យប្រសើរឡើង និងការធ្វើតេស្តឡើងវិញនៅកន្លែងដែលចាំបាច់។

មណ្ឌល និងក្រុមថែទាំរបស់យើងត្រូវផ្អាកការងាររបស់ពួកគេប៉ុន្មានថ្ងៃដើម្បីត្រៀមខ្លួនសម្រាប់ព្យុះព្រិលនៅដើមសប្តាហ៍នេះ និងដើម្បីបោសសម្អាតបរិវេណរបស់យើងដោយសុវត្ថិភាពពីព្រិលកម្រាស់ជាងប្រាំអ៊ីញដែលបានបន្សល់ទុក។ ការដឹកជញ្ជូន PPE និងផ្ទាំងណែនាំដទៃ

ទៀតពីឃ្លាំងរបស់យើងទៅសាលារៀនមួយចំនួន ក៏ត្រូវបានពន្យារដោយសារតែព្យុះនេះដែរ។ វិស្វករអគារឥឡូវនេះបានបន្តការងាររបស់ពួកគេនៅក្នុងសាលារៀន ហើយការដឹកជញ្ជូន PPE និងផ្ទាំងណែនាំសុវត្ថិភាពដទៃទៀតត្រូវបានរំពឹងទុកថានឹងត្រូវបានបញ្ចប់នៅដើមសប្តាហ៍ក្រោយ។ មេដឹកនាំជាន់ខ្ពស់របស់ខ្ញុំនិងខ្ញុំក៏បានបញ្ចប់ការត្រួតពិនិត្យសាលារៀនក្នុងសប្តាហ៍នេះ ដើម្បីជួយកំណត់និងរាយការណ៍អំពីការរៀបចំដែលត្រូវការ ចំពោះសុខភាពនិងសុវត្ថិភាពដែលនៅសល់នានា មុនពេលដែលសិស្សានុសិស្សត្រឡប់ទៅសាលារៀនវិញនៅថ្ងៃចន្ទ ទី2 ខែកុម្ភៈ។ ការប្តេជ្ញាចិត្តរបស់ខ្ញុំទៅអ្នកគឺថា ប្រសិនបើបន្ទប់មិនទាន់រួចរាល់ យើងនឹងមិនប្រើប្រាស់វាទេ។ ប្រសិនបើសាលារៀនមិនទាន់រួចរាល់ យើងនឹងមិនបើកដំណើរការវាទេ។

យើងបន្តធ្វើការជាមួយនឹងនាយកដ្ឋានសុខភាពសាធារណៈទីក្រុង Philadelphia ទៅលើផែនការធ្វើតេស្តយ៉ាងឆាប់រហ័សសម្រាប់សិស្សានុសិស្ស និងបុគ្គលិក និងសម្រាប់បុគ្គលិកមណ្ឌលសិក្សាធិការទាំងអស់ ដើម្បីទទួលបានវ៉ាក់សាំងជំងឺ COVID-19 ឲ្យបានឆាប់តាមដែលអាចធ្វើបាន។ នៅពេលដែលវ៉ាក់សាំងអាចប្រើប្រាស់បាន យើងនឹងបើកដំណើរការទីតាំងសាលារៀននៅទូទាំងទីក្រុង ដើម្បីឲ្យបុគ្គលិករបស់យើងអាចទទួលបានវ៉ាក់សាំងដោយងាយស្រួលនិងដោយឥតសង្ស័យតាមដំណាក់កាល ប្រសិនបើពួកគេជ្រើសរើសធ្វើដូច្នេះ។

យើងត្រូវបានទំនាក់ទំនងដោយគ្រួសារ PreK-2 ជាច្រើនដែលដើមឡើយបានជ្រើសរើសការសិក្សាតាមប្រព័ន្ធអនឡាញ ប៉ុន្តែឥឡូវនេះចាប់អារម្មណ៍ទៅលើគំរូសិក្សាបែបចម្រុះវិញ។ សូមជ្រាបថា យើងកំពុងធ្វើការទៅលើដំណើរការនៃការចុះឈ្មោះ ហើយនឹងចែករំលែកព័ត៌មានឲ្យបានឆាប់រហ័សនៅពេលដែលយើងបានធ្វើការលម្អិតទៅលើវា។

ដូចដែលខ្ញុំធ្លាប់បាននិយាយជាច្រើនដងរួចមកហើយ សុខភាពនិងសុខុមាលភាពរបស់អ្នកទាំងអស់គ្នានៅក្នុងសាលារៀនរបស់យើងគឺ និងនៅតែជាអាទិភាពខ្ពស់បំផុតរបស់យើង ខណៈពេលដែលយើងបើកទ្វារដំណើរការសាលារៀនរបស់យើងបន្តិចម្តងៗនិងដោយប្រុងប្រយ័ត្នទៅសិស្សានុសិស្សនិងបុគ្គលិកជាលើកដំបូងក្នុងអំឡុងពេលជិតមួយឆ្នាំកន្លងមក។ វានឹងមិនល្អឥតខ្ចោះទេ។ គ្មានអ្វីដែលល្អឥតខ្ចោះទេ។ ប៉ុន្តែតាមរយៈការធ្វើការងាររួមគ្នា ដោយអ្នកទាំងអស់គ្នាធ្វើការងាររបស់ពួកគេ យើងអាចធ្វើការងារនេះបានដោយសុវត្ថិភាព។

ដោយសេចក្តីគោរពរាប់អាន

William R. Hite Jr., Ed.D.
ស្នងការ
មណ្ឌលសិក្សាធិការនៃក្រុង Philadelphia